សូមជម្រាបសួរនេះជាការពន្យល់ទៅលើអត្ថន័យនៃការសំពះនៅក្នុងប្រទេសខ្មែរ ពាក្យថា សំពះ
គឺមានន័យថាគឺជាការដែលយើងលើកដៃទាំងសងខាង លើកដៃប្រណមផ្តុំគ្នា ហើយលើកមកខាងលើ
ហើយការសំពះគឺជាវិធីមួយ ឬក៏មធ្យោបាយមួយដែលសម្តែងនូវការអរគុណ ឬក៏ការជម្រាបសួរ
អញ្ចឹងគឺក្នុងការពេលដែលជួបគ្នា ប្រជាជនខ្មែរគឺការជួបគ្នាគឺប្រើប្រាស់ការសំពះ
អញ្ចឹងគឺការសំពះដែលបង្ហាញអំពីអត្ថន័យ បង្ហាញពីការជម្រាបសួរ ជួបគ្នាជាលើកដំបូង
ឬក៏ការស្វាគមន៍គ្នាគឺសំពះ ហើយការសំពះក៏ប្រើសម្រាប់ការសុំទោស [...]ប្រើសំពះ។
អញ្ចឹងគឺការសំពះ គឺជាការដឹងគុណ ហើយនឹងបង្ហាញអំពីការសុំទោស [...] ហើយនិងការជម្រាបសួរ
[...] រាក់ទាក់គ្នាការជម្រាបសួរ ការដឹងគុណ អរគុណ ហើយនិងការសុំទោស អញ្ចឹង
ការសំពះគឺប្រើក្នុងឱកាសដូចជា ការជួបគ្នា ជម្រាបសួរ ជួបគ្នា រាក់ទាក់ស្វាគមន៍គ្នា គឺសំពះ
ហើយការសំពះក៏ប្រើសម្រាប់ពេលដែលយើងធ្វើខុស ឧទាហរណ៍ថាក្មេងឬ ក៏អ្នកណាម្នាក់ធ្វើខុស
គឺយើងប្រើការសំពះនេះដែរ គឺបង្ហាញអំពីការសោកស្តាយ ការសុំទោស [...] សំពះ។
ហើយមួយទៀត គឺយើងសំពះនៅពេលដែលយើងអរគុណ ដឹងគុណពេលអ្នកណាឲ្យរបស់
ឬក៏អ្នកណាដែលធ្វើការល្អសម្រាប់យើងគឺយើងដឹងគុណ គឺ អរគុណ គឺសំពះអរគុណ។
ហើយការសំពះជាទូទៅគឺមាន ៥ បែប គឺមានន័យថាការសំពះគឺបង្ហាញអំពីឋានៈ ឬក៏កាលៈទេសៈ
ឬក៏ពេលវេលាខុសគ្នា ហើយ ក្នុងនោះការសំពះគឺមាន ៥ បែប អញ្ចឹងគឺយើងប្រើការសំពះនេះ
គឺសម្រាប់បង្ហាញអំពីទី ១ យើងដឹងហើយសំពះគឺដើម្បីជួបគ្នា សំពះជម្រាបសួរ សំពះសុំទោស
សំពះអរគុណ។ តែការសំពះនេះផងដែរគឺមាន ៥ បែប គឺមានន័យថាបង្ហាញអំពីកាលៈទេសៈ ៥
ខុសគ្នា

ទី ១ ការសំពះគឺ យើងប្រើម្រាមដៃទាំងសងខាង គឺយើងប្រើបាតដៃទាំងសងខាងនិងផ្តុំចូលគ្នា
អញ្ចឹងគឺសំពះ គឺ លើកដៃទាំងសងខាង ដែលយើងផ្តុំចូលគ្នា
និងហើយពេលដែលយើងលើកដៃកាន់តែខ្ពស់ អញ្ចឹងគឺជាការសំពះព្រះ ឬក៏គ្រឿងសក្ការបូជាផ្សេងៗ
អញ្ចឹងគឺសំពះ សំពះព្រះ សំពះព្រះដូចជាព្រះពុទ្ធ ឬក៏ការបន់ស្រន់ បួងសួង ឬក៏វត្ថុសក្តិសិទ្ធ
វត្ថុសក្តិសិទ្ធនឹងគឺសំដៅទៅលើអបិ្បយជំនឿ ដូចជាការជឿទៅលើអ្វីមួយ
ជឿថាដែលអាចនិងជួយបាននិងគឺ ការបន់ស្រន់ អញ្ចឹងដូចជា ប្រជាជនខ្មែរ
ពេលដែលគាត់ចង់បានអ្វីមួយ គាត់បន់ស្រន់ គាត់មានជំនឿ ឬក៏យើងហៅថា អបិ្បយជំនឿ
អបិ្បយជំនឿគឺជាការជឿទៅលើអ្វីមួយដោយមិន [...] មិនបានដឹងពិតប្រាកដ មានន័យថា
អបិ្បយជំនឿជឿទៅលើរបស់សក្តិសិទ្ធ ឬក៏ពេលខ្លះយើងជឿទៅលើព្រះពុទ្ធសាសនា
អញ្ចឹងការបន់ស្រន់ ការថ្វាយបង្គំព្រះ គឺការសំពះនេះ
គឺដៃទាំងសងខាងលើកទៅដល់ថ្ងាសលើកឲ្យខ្ពស់ទៅដល់ថ្ងាស អញ្ចឹងគឺបង្ហាញអំពី ការសំពះនិងគឺ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ជាទូទៅ ពេលដែលយើងប្រើសម្រាប់ថ្វាយបង្គំព្រះ ឬក៏វត្ថុសក្តិសិទ្ធ ឬក៏អប្បិយជំនឿ[...]ផ្សេងៗ [...]
ការបន់ស្រន់ គឺសំពះគឺលើកដៃទាំងសងខាងគឺខ្ពស់មកដល់ថ្ងាស។

ហើយសំពះមួយទៀតគឺពេលដែលយើងសំពះស្តេច ឬក៏ព្រះសង្ឃ
អញ្ចឹងស្តេចក៏ជាអ្នកដែលមានឋានៈខ្ពស់ដែលក្នុងប្រទេសខ្មែរ។
គឺស្តេចគឺមាន[...]ខ្ពស់បំផុតបន្ទាប់ពីព្រះមកគឺស្តេច ហើយស្តេចហើយនិងព្រះសង្ឃ
ស្តេចនិងព្រះសង្ឃ គឺដៃទាំងសងខាង នឹងគឺត្រឹមតែច្រមុះទេ គឺត្រឹមច្រមុះ សំពះស្តេច ឬក៏ព្រះសង្ឃ។

ហើយសំពះមួយទៀតពេលដែលយើងសំពះឪពុកម្តាយ គ្រូ បងប្អូន
ឬក៏អ្នកដែលមានវ័យចំណាស់ជាងដូចជា ជីដូនជីតា ឪពុកម្តាយ អ្នកដែលមានវ័យចំណាស់ជាង បង
[...] អញ្ចឹងអ្នកទាំងអស់គឺមានអាយុច្រើនជាងយើង អញ្ចឹងដៃគឺមកត្រឹមមាត់ ដាក់មកត្រឹមមាត់
ការសំពះដៃទាំងសងខាងគឺដាក់មកត្រឹមមាត់។

ហើយសំពះមួយទៀត មួយបែបទៀតគឺ បង្ហាញពីឋានៈតួនាទីដែលគឺ សំពះអ្នកដែលមានឋានៈទាប
ឋានៈប្រហែលយើង គឺអ្នកដែលមានអាយុស្មើយើង ឬក៏ឋានៈ[...] ឋានៈដូចយើងដែរ។
អញ្ចឹងសំពះនឹងគឺត្រឹមចង្កា ក្រោមពីមាត់[...]ត្រឹមចង្កា ដៃទាំងសងខាងគឺសំពះត្រឹមចង្កា

ហើយសំពះចុងក្រោយគឺសម្រាប់អ្នកដែលមានឋានៈតួនាទីទាបជាងយើង
ឧទាហរណ៍អ្នកដែលមានអាយុតិចជាងយើង ដូចជាប្អូន ឬក៏ក្មេងៗ
ឬក៏អ្នកដែលមានឋានៈតួនាទីក្នុងសង្គមទាបជាងយើង គឺសំពះនៅត្រឹមដើមទ្រូង។

អញ្ចឹងសរុបសេចក្តីមកគឺការសំពះនៅក្នុងប្រទេសខ្មែរ គឺបង្ហាញអំពី គឺបង្ហាញ
គឺប្រើសម្រាប់ការជួបគ្នា ការស្វាគមន៍គ្នា ដូចជា ការសំពះជម្រាបសួរ សំពះជម្រាបលា
ហើយសំពះពេលដែលយើងអរគុណ ហើយនិងសំពះពេលដែលយើងសុំទោស
ហើយការសំពះនេះទៀតគឺប្រើ [...]គឺមានលក្ខណៈ ៥ បែបដែលប្រើក្នុងកាលៈទេសៈខុសគ្នា
គឺសំដៅទៅលើអ្នកដែលតាមឋានៈខុសៗគ្នាអញ្ចឹង អ្នកដែលខ្ពស់ជាងគេគឺព្រះ
បន្ទាប់មកទៀតគឺស្តេច ឬក៏ព្រះសង្ឃ បន្ទាប់មកទៀតគឺឪពុកម្តាយ ឬក៏អ្នកដែលមានអាយុច្រើនជាង
ជីដូនជីតា ឪពុកម្តាយ បន្ទាប់មកទៀតអ្នកដែលមានឋានៈស្មើយើង ឬក៏អាយុស្មើយើង
ហើយនឹងចុងក្រោយគឺអ្នកដែលមានឋានៈទាបជាងយើង ឬក៏អ្នកដែលមានអាយុតិចជាងយើង
ហើយខ្ញុំក៏សូមបញ្ចប់ទៅការពិពណ៌នាទៅលើការសំពះនៅក្នុងប្រទេសខ្មែរនេះ ដោយប៉ុណ្ណេះដែរ
សូមអរគុណ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.